# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពាក្យរបស់ព្រះពុទ្ធសាសនាថា និស្ស័យនិងឧបនិស្ស័យ

web site: www.hoksavann,org

ថ្ងៃទី២ តុលា ២០០៦

ពាក្យថានិស្ស័យនិងឧបនិស្ស័យ ទាំងពីរនេះមានលក្ខណៈខុសគ្នា ។ ពាក្យថានិស្ស័យប្រែតាមពាក្យធម្មតាថា ពឹងផ្អែកឬពឹងអាស្រ័យ ដូចជាកុលបុត្រដែលបានបួសហើយភ្លាម ព្រះឧបជ្ឈាយ៍ឲ្យនិស្ស័យ៤គឺ អ្នកបួសត្រូវប្រើសំពត់បង្សុកូល ដើរបិណ្ឌបាត្រនៅក្រោមម្លប់ឈើ ប្រើថ្នាំកែរោគ ។ អ្នកបួសត្រូវអាស្រ័យបច្ច័យ៤នេះទើបរស់នៅបាន នេះជាពុទ្ធានុញ្ញាតខាងដើម ។ ចំណែកនៅក្នុងគម្ពីរអភិធម្មនិយាយថា និស្សយបច្ចយោ ប្រែថាធម៌ជានិស្ស័យ ជាបច្ច័យដល់គ្នានឹងគ្នា ដូចជារូបអាស្រ័យនាម ៗអាស្រ័យរូបជាដើម ។ រូបសំដៅបានរូបរាងកាយរបស់មនុស្សសត្វ ឯនាមសំដៅយកវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ ពាក្យធម្មតាថា អ្នកនេះមាននិស្ស័យនឹងអ្នកនោះ បានសេចក្ដីថា មាននិស្ស័យចិត្តថ្លើមស្រដៀងគ្នា ឬដូចគ្នា អាចនិយាយគ្នាបាន និងអាចពឹងពាក់គ្នាបាន ។

ពាក្យថាឧបនិស្ស័យ បានដល់អំពើល្អ ឬកុសលណាមួយដែលមានក្នុងចិត្តនៃមនុស្សសត្វ ជាប់តាំងពីអតីតកាលមក ។ កុសលធម៌ដែលជាឧបនិស្ស័យ បើនិយាយជាគោលមានបីយ៉ាងគឺ ទានូបនិស្ស័យ ប្រែថាឧបនិស្ស័យដោយការឲ្យទាន, សីលូបនិស្ស័យ ប្រែថាឧបនិស្ស័យដោយការរក្សាសីល, ភាវនូបនិស្ស័យប្រែថាឧបនិស្ស័យឬកុសលធម៌ដោយការភាវនា គឺការអប់រំចិត្តដោយសមថភាវនា និងវិបស្សនាភាវនា ។ ការឲ្យវត្ថុផ្សេងៗ ឬការប្រាប់មធ្យោបាយល្អ មធ្យោបាយនាំទៅរកសេចក្ដីសុខចំរើន ដែលហៅថាធម្មទានដល់អ្នកដទៃ ហៅថាទានូបនិស្ស័យ ។ ការវៀរចាកអំពើអាក្រក់តាមផ្លូវកាយនិងវាចា ដោយការរក្សាសីល៥សីល៨ជាដើម ហៅថាសីលូបនិស្ស័យ គឺការវៀរចាកបានពេលណាឈ្មោះថាសីលូបនិស្ស័យពេលនោះ ។ ការអប់រំចិត្តរហូតកើតសមាធិចិត្ត និងឃើញច្បាស់នូវសង្ខារ គឺខន្ធប្រាំជាអនិច្ចំ ទុក្ខំ និងអនត្តាដោយផ្លូវវិបស្សនាឈ្មោះថា ភាវនូបនិស្ស័យ ។ ឧបនិស្ស័យនោះ ពុំមែននិយាយតែក្នុងអតីតៈទេ គឺនិយាយការកសាងក្នុងកាលទាំងបី ឲ្យតែបង្កើតមានទាន

សីលភាវនាពេលណា ឈ្មោះថាមានឧបនិស្ស័យពេលនោះហើយ ។ ព្រះនាមរបស់ព្រះពុទ្ធមួយបទថា បុរិសទម្មសារថី ដែលប្រែថា ព្រះពុទ្ធជានាយសារថីទូន្មាននូវសត្វដែលគួរទូន្មានបាននោះ មានសេចក្ដីថា សត្វដែលបានធ្វើទាន រក្សាសីល ចំរើនភាវនាពីមុនមក ទើបព្រះអង្គទូន្មានបាន គឺសត្វមានទានូបនិស្ស័យ សីលូបនិស្ស័យ និងភាវនូបនិស្ស័យនេះឯង ។ សត្វដែលគួរទូន្មានបាននោះ គឺបើព្រះអង្គទេសនាពន្យល់ធម៌ណាមួយ សត្វនេះយកចិត្តទុកដាក់ស្ដាប់យកពាក្យនោះទៅពិចារណាឲ្យយល់សេចក្ដីពិត ហើយប្រតិបត្តិតាម ព្រោះសត្វនោះធ្លាប់ប្រព្រឹត្តល្អតាំងពីដើមមក ។ ផ្ទុយទៅវិញ បើសត្វនោះកំពុងលង់ក្នុងមិច្ឆាទិដ្ឋិ ការយល់ខុសហើយប្រព្រឹត្តតាមការយល់ខុសរបស់ខ្លួន សត្វខ្លះព្រះអង្គអាចទៅប្រោសឲ្យយល់ត្រូវជាសម្មាទិដ្ឋិវិញបាន ប៉ុន្តែបើសត្វនោះលង់ក្នុងមិច្ឆាទិដ្ឋិដ៏ជ្រៅធ្លាក់និយតមិច្ឆាទិដ្ឋិហើយ ព្រះអង្គពុំអាចកែឲ្យយល់ត្រូវវិញបានឡើយ ។៚

❑ ❑

❑